# របាយការណ៍សង្ខេបកម្មវិធីទី៣៖
# ពិពិធកម្មសកម្មភាពសេដ្ឋកិច្ចជនបទ

## ១. សេចក្តីផ្តើម:

អំឡុងពេលជិតពីរទសវត្សចុងក្រោយនេះ រាជរដ្ឋាភិបាលធានាបានកំណើនសេដ្ឋកិច្ច ក្នុងអត្រាជាមធ្យមប្រចាំឆ្នាំ ក្នុងរង្វង់ ៥,២% ប្រកបដោយចីរភាព ធន់នឹងវិបត្តិ តាមរយៈការធ្វើពិពិធកម្មនៃមូលដ្ឋានសេដ្ឋកិច្ចថ្មី ដោយទូលំទូលាយ និងភាពប្រកួតប្រជែង ជាមួយនឹងការថែរក្សាបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចដោយគ្រប់គ្រងអត្រាអតិផរណាឲ្យនៅទាប និងការគ្រប់គ្រងបំណុលសាធារណៈដោយគត់មត់បង្កើតការងារនិងមុខរបរឲ្យបានកាន់តែសម្បូរបែប ទាំងបរិមាណ ទាំងគុណភាព និងបង្កើនភាពងាយរកបានទីផ្សារ ទាំងការងារ ទាំងផលិតផល និងជំរុញការវិនិយោគ សហគ្រិនភាពសម្រាប់ធានាចីរភាពនៃកំណើនសេដ្ឋកិច្ច ព្រមទាំងវឌ្ឍនភាព និងវិបុលភាពជូនប្រជាពលរដ្ឋ។

ដូច្នេះហើយឆ្នាំ២០២២នេះ គឺជាឆ្នាំទី៤ នៃការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជនបទ ២០១៩-២០២៣ ដែលក្រសួងអភិវឌ្ឍន៍ជនបទបានដាក់ចេញនូវគោលបំណងគោលនយោបាយចម្បងគឺ **"ការលើកកម្ពស់គុណភាពនិងគុណតម្លៃនៃជីវិតរស់នៅរបស់ប្រជាជនជនបទប្រកបដោយបរិយាប័ន្នទាំងផ្នែកសេដ្ឋកិច្ច សង្គម និងវប្បធម៌"** និងបានកំណត់យកសសរស្តម ៤ ដែលដើរតួជាកម្មវិធីអាទិភាពគឺ៖ ១) ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តនិងគមនាគមន៍, ២) ការកែលម្អលក្ខខណ្ឌនៃការរស់នៅរបស់សហគមន៍ជនបទ, ៣)ការធ្វើពិពិធកម្មសកម្មភាពសេដ្ឋកិច្ចជនបទ,និង៤) ការពង្រឹងសេវាគាំទ្ររដ្ឋបាលនិងកិច្ចការទូទៅ។ ក្នុងចំណោមសសរស្តម្ភទាំង៤ ការធ្វើពិពិធកម្មសកម្មភាពសេដ្ឋកិច្ចជនបទ គឺជាកម្លាំងចលករមួយកំពុងរួមចំណែកយ៉ាងសកម្ម ក្នុងការជំរុញឲ្យមានការផ្លាស់ប្តូរជីវភាពរស់នៅរបស់ប្រជាជនជនបទ តាមរយៈការបណ្តុះបណ្តាលជំនាញមូលដ្ឋាន, ការផ្តល់ឥណទានខ្នាតតូច, ការបង្កើតមុខរបរខ្នាតតូច, ការអភិវឌ្ឍភូមិចម្រុះ, ការទទួលស្គាល់អត្តសញ្ញាណភូមិជនជាតិដើមភាគតិច។ ទោះស្ថិតក្នុងបរិបទប្រឈមនឹងការរីករាលដាលជំងឺកូវីដ១៩ យ៉ាងណាក៏ដោយ ជាលទ្ធផលឆ្នាំ២០២៣

កម្មវិធីទី៣ បានសម្រេចលទ្ធផលល្អ ......% បើធៀបនឹងសូចនាករក្នុងឆ្នាំ។

ទន្ទឹមនឹងនោះយើងក៏នៅមានបញ្ហា ការប្រឈម និងទិសដៅមួយចំនួនសម្រាប់ដោះស្រាយក្នុងឆ្នាំបន្ទាប់ដូចជា៖ ១) ការវិភាជថវិកាសម្រាប់កម្មវិធីនៅមានកម្រិត, ២) ជំងឺកូវីដ-១៩ នៅតែបន្តឆ្លង, ៣) ការខ្វះទីផ្សារកសិផល, ៤) សេដ្ឋកិច្ចជាតិជាដុលមានការកើនឡើង តែជីវភាពរបស់ប្រជាពលរដ្ឋជនបទនៅតែស្ថិតក្នុងភាពក្រីក្រ, ៥) ការកើនឡើងបំណុលរបស់ប្រជាកសិករ។

## ២. លទ្ធផលក្នុងឆ្នាំ២០២២

ដោយសារវិបត្តិជំងឺកូវីដ១៩ នៅតែបន្តអូសបន្លាយ ធ្វើឲ្យថវិកាកម្មវិធីទី៣ ឆ្នាំ២០២២ ត្រូវបានរិភាជត្រឹមចំនួន ២ ៩៤៤,៦លានរៀល ថយចុះចំនួន ៧២២,៥លានរៀល ស្មើនឹង ១៩,៧% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១ ដែលមានចំនួន ៣ ៦៦៧,១លានរៀល អនុវត្តបានចំនួន ......លានរៀល ស្មើនឹង ......% ធៀបនឹងច្បាប់ឆ្នាំ២០២២ ដោយសម្រេចគោលដៅបានចំនួន ......% ។

លទ្ធផលខាងលើនេះបានជះឥទ្ធិពលដល់ផែនការយុទ្ធសាស្ត្រថវិកា និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជនបទរយៈពេល៥ឆ្នាំផងដែរ។ ខាងក្រោមនេះជាលទ្ធផលរបស់អង្គភាពទាំង៥៖

ឯកតា:លានរៀល

| នាយកដ្ឋាន | ច្បាប់ហិរញ្ញវត្ថុ | អនុវត្តថវិកាបាន | %ថវិកា | %សកម្មភាព |
|---|---|---|---|---|
| **សរុបរួម** | **២ ៩៤៤,៦** | | | |
| អភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ | ៣៣៧,៣ | ២៩២,៧ | ៨៦,៨% | ៨៣,០% |
| អភិវឌ្ឍន៍សហគមន៍ជនបទ | ៩០៧,២ | ...... | ...... | ...... |
| អភិវឌ្ឍន៍ជនជាតិភាគតិច | ៣០០,០ | ២៤៣,៩ | 81,32 | ៨៩,០% |
| បណ្តុះបណ្តាលនិងស្រាវជ្រាវ | ៧៧៣,០ | ...... | ...... | ៩៣,១% |
| មន្ទីរអភិវឌ្ឍន៍រាជធានីខេត្ត | ៦២៧,១ | ...... | ...... | ...... |

**អនុកម្មវិធីទី១ នៃកម្មវិធីទី៣ ការជំរុញបង្កើតការងារ និងមុខរបរនៅជនបទ** អនុវត្តសកម្មភាពបាន ៧៨,៦% និងប្រើប្រាស់ថវិកាអស់ចំនួន ៩៦,៤ លានរៀល ស្មើនឹង ៨១,៤% ធៀបច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០២២ ។ នាយកដ្ឋានបានគាំទ្រដល់សកម្មភាពបង្កើតការងារនិងមុខរបរ ដោយឆ្នាំ ២០២២ សម្រេចបាន តាមរយៈសិក្ខាសាលាផ្តល់គំនិតក្នុងការផ្តួចផ្តើមអាជីវកម្មខ្នាតតូច ២_លើក ការផ្លាស់ប្តូរបទពិសោធន៍ជោគជ័យនិងបញ្ហាប្រឈមរបស់សហគមន៍សន្សំប្រាក់ ១លើក ការពង្រឹងសមត្ថភាពសហគមន៍សន្សំប្រាក់ ១លើក និងការពិនិត្យ តាមដានលើសកម្មភាពបណ្តុះបណ្តាល ៣លើក និងវគ្គបណ្តុះបណ្តាលជំនាញនិងភាពជាសហគ្រិន ១២ វគ្គ ក្នុងខេត្តគោលដៅចំនួន ៥ខេត្ត រួមមាន ខេត្តកំពង់ចាម កំពង់ឆ្នាំង តាកែវ កំពង់ធំ និងខេត្តសៀមរាប។ ធៀបនឹងគោលដៅ BSP ២០២២-២០២៤ ដែលគ្រោងអនុវត្តសកម្មភាព ២២ និងមានប្រជាពលរដ្ឋអ្នកចូលរួមទទួលផលចំនួន ៤៧៥ នាក់ គឺបានអនុវត្តជាក់ស្តែងបានចំនួន ១៩ លើក និងមានប្រជាជនចូលរួមចំនួន ៣៧៧ នាក់ ដែលប្រមាណ ៧៥% ទទួលបានការយល់ដឹង។ ជាមួយនឹងទំហំលទ្ធផលនេះ បើប្រៀបធៀប

នឹងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជនបទ ២០១៩-២០២៣ ក្នុងការបង្កើតមុខរបរនិងការងារឲ្យបាន ១,៥០០ នាក់ គឺនៅពុំអាចឆ្លើយតបបាននៅឡើយ។ ជាក់ស្តែងនាពេលបច្ចុប្បន្នបានបង្កើតក្រុមអ្នកផលិតសាប៊ូ បានចំនួន ២៤ក្រុម ស្មើនឹង ១២៣គ្រួសារ និងការផលិតជាលក្ខណៈឯកជនមាន ១០នាក់ ដែលនេះហាក់នៅឆ្ងាយពីគោលដៅដែលបានកំណត់សម្រាប់រយៈពេល ៥ឆ្នាំ ត្រូវមានសហគ្រិនប្រមាណ ១៥០០នាក់។

**អនុកម្មវិធីទី ២ នៃកម្មវិធីទី ៣ ការជំរុញសកម្មភាពសេដ្ឋកិច្ចគ្រួសារនៅជនបទ** អនុវត្តសកម្មភាពបាន ៨៧,៥% និងប្រើប្រាស់ថវិកាអស់ចំនួន ១៩៦,៣ លានរៀល ស្មើនឹង ៨៩,៧% ធៀបច្បាប់ឆ្នាំ ២០២២ ។ សកម្មភាពដែលនាយកដ្ឋានសម្រេចបានក្នុងឆ្នាំ ២០២២ រួមមាន ការចែករំលែកការយល់ដឹង បទពិសោធន៍ពីផលិតផលជនបទ និងការងារផេណាទានជនបទ ចំនួន ៣លើក ការត្រួតពិនិត្យលើដំណើការផេណាទានជនបទ និងសកម្មភាពផ្សេងៗ ៥លើក ការងារសាងសង់ផ្សារជនបទដំហ៊ាន ២ ដោយមានប្រជាពលរដ្ឋចូលរួមចំនួន ១០២ នាក់ និងការតាំងពិពណ៌ផលិតផលជនបទ ១លើក មានប្រជាពលរដ្ឋចូលរួមទស្សនាប្រហែល ២ ០០០នាក់ ក្នុងខេត្តគោលដៅ ខេត្តកំពត តាកែវ បាត់ដំបង សៀមរាប កំពង់ចាម កំពង់ឆ្នាំង ត្បូងឃ្មុំ និងខេត្តស្វាយរៀង។

**អនុកម្មវិធីទី៣ នៃកម្មវិធីទី៣ ការបណ្តុះបណ្តាលធនធានមនុស្ស និងជំនាញអាជីព** អនុវត្តសកម្មភាពបាន ៩៣,១% និងប្រើប្រាស់ថវិកាអស់ចំនួន ...........លានរៀល ស្មើនឹង .....% ធៀបច្បាប់ឆ្នាំ២០២២ ។ សកម្មភាពដែលនាយកដ្ឋានបានអនុវត្តគឺ ការបណ្តុះបណ្តាលធនធានមនុស្ស និងជំនាញមូលដ្ឋាន ដោយបានបែងចែកសកម្មភាពគន្លឹះចំនួន ២ គឺ(១).ការអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការ ដោយបានកំណត់ជាចង្កោមសកម្មភាពចំនួន ៤ ដែលត្រូវបានអនុវត្តដោយនាយកដ្ឋាន ដោយបានបើកវគ្គបណ្តុះបណ្តាលចំនួន ៣ វគ្គ ដែលមានមន្ត្រីរាជការចូលរួមសរុបចំនួន ៦៩៦នាក់ (ស្រីចំនួន ១៧ នាក់) និងបើកវគ្គសិក្ខាសាលាមន្ត្រីរាជការនៃក្រសួងអភិវឌ្ឍន៍ជនបទបានចំនួន ១ ៣៩០នាក់ (ស្រី ១៧៨ នាក់), បានបន្តការសិក្សាស្រាវជ្រាវលើឯកសារនានា និងចុះស្វែងយល់តាមមន្ទីរអភិវឌ្ឍន៍ជនបទ និងការងារផ្សព្វផ្សាយបានចំនួន ១៨៤ លើក និង (២).ការបណ្តុះបណ្តាលជំនាញមូលដ្ឋាន បានកំណត់ចង្កោមសកម្មភាពចំនួន ១ អនុវត្តដោយមជ្ឈមណ្ឌលបណ្តុះបណ្តាលជំនាញមូលដ្ឋាននៃខេត្តទាំង ១១ គឺបានបើកវគ្គបណ្តុះបណ្តាលរយៈពេលវែងចំនួន ១៤ វគ្គ និងវគ្គខ្លីចំនួន ៧៩ វគ្គ សរុបចំនួន ៩៣ វគ្គ ដែលមានសិក្ខាកាមសរុបចំនួន ១ ៧៦០ នាក់ (ស្រី ៧៦៤ នាក់) ស្មើនឹង ៨៦,១% ធៀបនឹងសូចនាករគោលដៅឆ្នាំ ២០២២ ដែលមានចំនួន ១០៨ វគ្គ ។

**អនុកម្មវិធីទី៤ នៃកម្មវិធីទី៣ ជំរុញការអភិវឌ្ឍចម្រុះសម្រាប់សហគមន៍ជនបទ** ការអនុវត្តសកម្មភាពបាន ......% និងប្រើប្រាស់ថវិកាអស់ចំនួន ......... លានរៀល ស្មើនឹង .....% ធៀបច្បាប់ឆ្នាំ២០២២ ។ នាយកដ្ឋានបានអនុវត្តសកម្មភាព (១).ការពង្រឹងសមត្ថភាពគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ (គ.អ.ភ)

សម្រេចបាន ......% ដោយបានបណ្តុះបណ្តាលពង្រឹងសមត្ថភាពគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ (គ.អ.ភ) ស្តីពីការធ្វើផែនការសកម្មភាពអភិវឌ្ឍន៍ភូមិ និងសញ្ញាណចលនាភូមិថ្មីបានចំនួន ៣០ វគ្គ ដែលមានសិក្ខាកាមសរុបចំនួន ៦០០ នាក់ (ស្រី ២១១ នាក់) មកពី ១៦៩ ភូមិ, (២).ការអភិវឌ្ឍភូមិចម្រុះ សម្រេចបាន ......% ដោយបានគាំទ្រសកម្មភាពអភិឌ្ឍន៍ភូមិចម្រុះរួមមាន កូនឈើហូបផ្លែចម្រុះបានចំនួន ៤ ០០០ ដើម ស្មើនឹង ៥០០ គ្រួសារ ផ្តល់ពូជបន្លែចម្រុះបានចំនួន ៩ ០០០ ស្មើនឹង ៥០០ គ្រួសារ និងស្រះគ្រួសារបានចំនួន ៥០ ស្រះ ស្មើនឹង ៥០ គ្រួសារ លើភូមិគោលដៅចំនួន ០៥ ភូមិ នៃខេត្តគោលដៅចំនួន ០៥ រួមមាន ខេត្តព្រៃវែង ខេត្តកំពត ខេត្តត្បូងឃ្មុំ ខេត្តស្ទឹងត្រែង និងខេត្តសៀមរាប (៣).ការលើកកម្ពស់សន្តិសុខស្បៀងជាលក្ខណៈគ្រួសារ សម្រេចបាន ......% ដោយបានផ្តល់ពូជបន្លែចម្រុះចំនួន ៣១៥ គ្រួសារ បានផ្តល់សម្ភារធ្វើពាងជីកំប៉ុស្តចំនួន ៣១៥ គ្រួសារ និងបើកវគ្គបណ្តុះបណ្តាលដល់គ្រួសារសហគមន៍ស្តីពី សួនដំណាំគ្រួសារ និងរបៀបធ្វើជីកំប៉ុស្តបានចំនួន ០៥ វគ្គ មានសិក្ខាកាមចូលរួមចំនួន ១០០ នាក់ (ស្រី ៨២ នាក់) ក្នុងខេត្តគោលដៅចំនួន ២ រួមមានខេត្តកែប និងខេត្តសៀមរាប (៤).ការអប់រំក្រៅប្រព័ន្ធដល់ប្រជាពលរដ្ឋក្នុងសហគមន៍ សម្រេចបាន ......% ដោយបានបើកវគ្គបណ្តុះបណ្តាលការត្រៀមបង្ការ និងកាត់បន្ថយគ្រោះភ័យក្នុងសហគមន៍បានចំនួន ០៥ វគ្គ ដែលមានសិក្ខាកាមចូលរួមចំនួន ១០០ នាក់ (ស្រី ៣៤ នាក់) មកពី ១០ ភូមិ ក្នុងខេត្តចំនួន ២ គឺខេត្តប៉ៃលិន និងខេត្តបន្ទាយមានជ័យ (៥).ការពង្រឹងសកម្មភាពមជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទកម្ពុជា-កូរ៉េ សម្រេចបាន ......% ដោយបានបើកវគ្គបណ្តុះបណ្តាលចំនួន ០៩ វគ្គ មានសិក្ខាកាមចូលរួមសរុបចំនួន ៣៤០ នាក់ (ស្រី ១៦១ នាក់) ក្នុងនោះដែរ មជ្ឈមណ្ឌលក៏បានសហការអនុវត្តគម្រោងរវាងអង្គការម៉ារីយ៉ាអ៊ីនធើណាសិនណាល់ (Merry Year International) ដើម្បីធ្វើការបណ្តុះបណ្តាលបន្ថែមបានចំនួន ០៧ វគ្គ មានសិក្ខាកាមចូលរួមសរុបចំនួន ១៣៩ នាក់ (ស្រី ៥៧ នាក់) (៦). ការគាំទ្រសកម្មភាពមជ្ឈមណ្ឌលអភិវឌ្ឍន៍សហគមន៍ សម្រេចបាន ......% ដោយបានបើកវគ្គបណ្តុះបណ្តាលនៅក្រៅមជ្ឈមណ្ឌលបានចំនួន ៣៤ វគ្គ មានសិក្ខាកាមសរុបចំនួន ៦៨០ នាក់ ស្រី ២៨៣ នាក់ នៅខេត្តតាកែវ និងខេត្តកំពង់ស្ពឺ ។ ដោយឡែក មន្ទីរអភិវឌ្ឍន៍ជនបទខេត្តបានចុះពង្រឹងតួនាទី ភារកិច្ច គ.អ.ភ បានចំនួន ៦៩ វគ្គ មានសិក្ខាកាមសរុបចំនួន ២ ១៩២ នាក់ (ស្រី ៧៧៤ នាក់) មកពី ៣៧៣ ភូមិ។

**អនុកម្មវិធីទី៥ នៃកម្មវិធីទី៣ ការអភិវឌ្ឍ និងអភិរក្សជនជាតិដើមភាគតិច** ការអនុវត្តសកម្មភាពបាន ៨៩,០% និងប្រើប្រាស់ថវិកាអស់ចំនួន .......... លានរៀល ស្មើនឹង .........% ធៀបច្បាប់ឆ្នាំ២០២២ ។ នាយកដ្ឋានបានអនុវត្តចង្កោមសកម្មភាពចំនួន ៣ គឺ (១).កំណត់អត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិច អនុវត្តបាន ៩៤% ដោយបានចុះកំណត់អត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិចបានចំនួន ៧ សហគមន៍ នៃ ៤ខេត្តគោលដៅ រួមមានខេត្ត..........., រៀបចំបទបញ្ញាផ្ទៃក្នុងស្តីពីការដឹកនាំគ្រប់គ្រងការប្រើប្រាស់ដីសមូហភាពសហគមន៍ជនជាតិដើមភាគតិចចំនួន ០៤ សហគមន៍ (២).ពង្រឹង

សមត្ថភាព និងអភិវឌ្ឍន៍សហគមន៍ជនជាតិដើមភាគតិច អនុវត្តបាន ៩៧% ដោយបានរៀបចំប្រារព្ធទិវាអន្តរជាតិជនជាតិដើមភាគតិចពិភពលោកលើកទី ២៨ លើកទី ១៨ សម្រាប់កម្ពុជានៅខេត្តក្រចេះ, រៀបចំសិក្ខាសាលាតម្រង់ទិសស្តីពីនីតិវិធីនៃការវាយតម្លៃកំណត់អត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិចនិងបូកសរុបលទ្ធផលការងារជាមួយអង្គការដៃគូអភិវឌ្ឍន៍បានចំនួន ០១ លើក និង(៣).រៀបចំសហគមន៍គម្រូជនជាតិដើមភាគតិច អនុវត្តបាន ៧៦,០% ដោយបានចុះសិក្សាការងារអត្តិភាពបង្កើតសហគមន៍គម្រូជនជាតិដើមភាគតិចបានចំនួន ០១ សហគមន៍នៅខេត្តមណ្ឌលគិរី។

**អនុកម្មវិធីទី៦ នៃកម្មវិធីទី៣ ការលើកកម្ពស់កម្រិតជីវភាពរស់នៅតាមជនបទដោយមន្ទីរជំនាញ ២៥** ការអនុវត្តសកម្មភាពបានចំនួន ......% ដោយប្រើប្រាស់ថវិកាអស់ចំនួន ....... លានរៀល ស្មើនឹង ...........% ធៀបច្បាប់ឆ្នាំ២០២២ ។ មន្ទីរបានអនុវត្ត...........................................

ទន្ទឹមនឹងនេះ កម្មវិធីទី ៣ ត្រូវបានទទួលថវិកាហិរញ្ញប្បទានដោយដៃគូរអភិវឌ្ឍន៍ចំនួន ៥ គម្រោង សម្រាប់បន្តអនុវត្តក្នុងឆ្នាំ ២០២២ ដែលមានទឹកប្រាក់សរុបចំនួន ......លានរៀល ដែលត្រូវបានបែងចែកទៅតាមគម្រោងដូចខាងក្រោម៖

**គម្រោងទី ១. គម្រោងបំពេញបន្ថែមលើគម្រោងសហប្រតិបត្តិការកាត់បន្ថយភាពក្រីក្រកម្ពុជា-ចិន** ត្រូវបានគ្រោងថវិកាសរុបចំនួន .........លានរៀល សម្រាប់ឆ្នាំ ២០២២ ត្រូវបានគ្រោងចំនួន.........លានរៀល សកម្មភាពដែលសម្រេចបានគឺ បានសាងសង់បង្គន់អនាម័យជូនប្រជាពលរដ្ឋបានចំនួន ១០០ បង្គន់ បានជួសជុលផ្ទះជូនប្រជាពលរដ្ឋក្រីក្របានចំនួន ១០០ ខ្នងផ្ទះ បានទិញសម្ភារអគ្គិសនី និងទំនាក់ទំនងភ្ជាប់បណ្តាញចូលផ្ទះជូនប្រជាពលរដ្ឋក្រីក្របានចំនួន ៧០ ខ្នងផ្ទះ និងបានសាងសង់រោងលាយល្បាយសម្រាប់ការវិចខ្ចប់ធ្វើជាកញ្ចប់បណ្តុះផ្សិតចំនួន ០២ ខ្នង។

**គម្រោងទី ២. គម្រោងពិពិធកម្មវិស័យកសិកម្មកម្ពុជា**
ត្រូវបានគ្រោងថវិកាសរុបចំនួន ១០១ ៦២៥លានរៀល សម្រាប់ឆ្នាំ ២០២២ ត្រូវបានគ្រោងចំនួន ១៦ ១៩២លានរៀល សកម្មភាពដែលសម្រេចបានគឺ បានសាងសង់រោងស្តុកបន្លែចំនួន ០៣ រោង បានទិញត្រាក់ទ័រម៉ាកចនឌាចំនួន ០១ គ្រឿង និងបានទិញជីគ្រាប់ចំនួន ៧៨០ បាវ។

**គម្រោងទី ៣. គម្រោងចែកចាយទឹកស្អាត ដើម្បីអនាគតទាំងអស់គ្នា**
ត្រូវបានគ្រោងថវិកាសរុបចំនួន .........លានរៀល សម្រាប់ឆ្នាំ ២០២២ ត្រូវបានគ្រោងចំនួន.........លានរៀល សកម្មភាពដែលសម្រេចបានគឺ គម្រោងបានផ្តល់ទុយោ និងការតភ្ជាប់បណ្តាញទឹកស្អាតព្រមទាំងកាយដីកប់ទុយោចំនួន ៣១ ៥០០ ម និងសម្ភារៈដំណរភ្ជាប់ បានផ្តល់កុំព្យូទ័រចំនួន ៤ គ្រឿង និងព្រីនធ័រចំនួន ៤

គ្រឿងជូនដល់សហគមន៍ទាំង ៤ និងបានបើកវគ្គបណ្តុះបណ្តាលស្តីពីការផ្លាស់ប្តូរផ្នត់គំនិត ដើម្បីបង្កើនប្រាក់ចំណូល ចំនួន ១០ វគ្គ។

**គម្រោងទី ៤. "ការកសាងភូមិសន្តិភាព តាមរយៈការអភិវឌ្ឍសហគមន៍ជនបទចម្រុះ"** (Building Peace Village Through Integrated Rural Community Development) មានរយៈអនុវត្តគម្រោងចំនួន ០៥ ឆ្នាំ (២០២២-២០២៦) ត្រូវបានគ្រោងថវិកាសរុបចំនួន ៤១ ០០០ លានរៀល តាមរយៈទីភ្នាក់ងារសហប្រតិបត្តិការកូរ៉េ (KOICA) ដែលនឹងអនុវត្តគម្រោងនៅខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ និងខេត្តប៉ៃលិន។ គម្រោងមានគោលបំណងលើកកម្ពស់លក្ខខណ្ឌរស់នៅ និងផ្តល់អាទិភាពដល់សហគមន៍ជនបទ បង្កើននិរន្តរភាពប្រាក់ចំណូលកសិកម្ម និងអភិបាលកិច្ចល្អនៃការអភិវឌ្ឍជនបទ។ ជាលទ្ធផលក្នុងឆ្នាំ ២០២២ នេះ គម្រោងបានចុះកិច្ចព្រមព្រៀងអនុវត្តគម្រោងបង្កើតគណៈកម្មការគ្រប់គ្រង និងអនុវត្តគម្រោងចុះសិក្សាលទ្ធភាពដើម្បីជ្រើសរើសភូមិគោលដៅអនុវត្តគម្រោង និងកំពុងដំណើរការជ្រើសរើសក្រុមការងារគ្រប់គ្រងគម្រោង។

**គម្រោងទី ៥. "ភូមិគំរូចលនាភូមិថ្មី"** (Saemaul Undong Model Villagers Project) មានរយៈពេលអនុវត្តគម្រោងចំនួន ០៥ ឆ្នាំ (២០២២-២០២៦) ត្រូវបានគ្រោងថវិកាសរុបចំនួន ៣ ៦៩០ លានរៀល តាមរយៈមជ្ឈមណ្ឌលចលនាភូមិថ្មីកូរ៉េ ដែលនឹងអនុវត្តគម្រោងនៅភូមិចំនួន ០៤ ក្នុងឃុំព្រៃរំដួល ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ។ គម្រោងមានគោលបំណងលើកកម្ពស់លក្ខខណ្ឌរស់នៅ និងផ្តល់អំណាចដល់សហគមន៍ជនបទ បង្កើននិរន្តរភាពកសិកម្ម និងការពង្រឹងសមត្ថភាព។ ជាលទ្ធផលក្នុងឆ្នាំ ២០២២ នេះ គម្រោងបានចុះកិច្ចព្រមព្រៀងអនុវត្តគម្រោងបង្កើតគណៈកម្មការគ្រប់គ្រង និងអនុវត្តគម្រោង និងបានរៀបចំសំណើផែនការសកម្មភាពអនុវត្តសកម្មភាពរបស់ភូមិ ។

## ៣. បញ្ហានិងការប្រឈម

### បញ្ហា

- ខ្វះទីផ្សារលក់កសិផល និងទីផ្សារការងារ
- ចរន្តនៃការទិញ លក់ដីធ្លីនៅតែបន្ត
- បំណុលគ្រួសាររបស់កសិករកើនឡើងក្នុងបរិបថជំងឺកូវីដ ១៩
- ជីវភាពខ្វះខាតធ្វើឱ្យប្រជាពលរដ្ឋមួយចំនួនចំណាកស្រុក ដែលឱ្យប៉ះពាល់ដល់ដំណើរការនៃការអនុវត្តសកម្មភាពអភិវឌ្ឍន៍នៅមូលដ្ឋាន

- ប្រជាកសិករ និងផលិតករ សិប្បករមិនទាន់ចងក្រងគ្នាជាសហករណ៍ (Cooperatives) នៅតែមានទស្សនពឹងផ្អែកលើជំនួយពីខាងក្រៅ
- ភូមិជនជាតិដើមមួយចំនួនឈានទៅបាត់បង់អត្តសញ្ញាណ
- នៅជនបទយុវជន មានតែកម្លាំងខ្វះជំនាញ

**ការប្រឈម**

- ការចរចាកញ្ចប់ថវិកាកម្រិតជំនាញ ផ្តោតលើមាតិកាថវិកា មិនផ្តោតលើសមិទ្ធកម្ម
- ដៃគូ និងអង្គការដែលធ្លាប់សហការនៅតាមបណ្តាខេត្តមួយចំនួន បានបញ្ចប់បេសកកម្ម ដែលនាំបន្ទុកមួយចំនួនបន្ថែមទៀតដល់នាយកដ្ឋាន
- ថវិកាសម្រាប់បណ្តុះបណ្តាលពុំទាន់ឆ្លើយតបទៅនឹងតម្រូវការរបស់សហគមន៍នៅឡើយ
- គ.អ.ភ ពុំមានស្នាក់ការសម្រាប់ធ្វើការងារ
- ស្ថាប័ន ឬអង្គការមួយចំនួន មិនប្រើប្រាស់ គ.អ.ភ ហើយបានបង្កើត និងប្រើប្រាស់ជនបង្គោលផ្សេងៗ
- ពុំសូវមានសមាសភាព គ.អ.ភ ជាស្ត្រី ដែលសារាចរណែនាំ ជំរុញសមាសភាពជាស្ត្រីចូលរួមឱ្យបានច្រើន
- សកម្មភាពគាំទ្រការអភិវឌ្ឍភូមិចម្រុះ និងសន្តិសុខស្បៀង ដែលមានការផ្តល់ពូជរុក្ខជាតិ ពូជសត្វស្រះត្រីគ្រួសារ និងសម្ភាររោងជីកំប៉ុស្តជាដើម ត្រូវបានដាក់ក្នុងផែនការលទ្ធកម្មរួមរបស់ក្រសួង ធ្វើឱ្យសកម្មភាពនេះពិបាកក្នុងការអនុវត្ត ឬមិនអាចអនុវត្តបាន។
- គម្លាតកិច្ចសហប្រតិបត្តិការរវាងនាយកដ្ឋានអភិវឌ្ឍន៍ជនជាតិដើមភាគតិច និងមន្ទីរអភិវឌ្ឍន៍ជនបទ អង្គការមិនមែនរដ្ឋាភិបាល ព្រមទាំងដៃគូ
- ចំណេះដឹង និងការចូលរួមរបស់ជនជាតិដើមភាគតិចនៅមានកម្រិត
- ភូមិគោលដៅមួយចំនួនពិបាកក្នុងការធ្វើដំណើរចុះសិក្សាកំណត់អត្តសញ្ញាណ
- ជនជាតិដើមមួយចំនួនពុំបង្ហាញពីអត្តសញ្ញាណរបស់ខ្លួន
- កង្វះថវិកាក្នុងការពន្លឿនការចុះកំណត់អត្តសញ្ញាណជនជាតិដើមភាគតិច
- ខ្វះអគារសិក្សាសមរម្យ កន្លែងសម្រាប់សិក្ខាកាម និងបុគ្គលិកស្នាក់នៅ និងរោងជាសម្រាប់ហាត់ការ
- ខ្វះគ្រូបង្គោល ដែលមានជំនាញច្បាស់លាស់ នៅក្នុងមជ្ឈមណ្ឌលបណ្តុះបណ្តាល ជំនាញមូលដ្ឋាន
- ខ្វះឧបករណ៍ ឬសម្ភារឧបទ្ទេសសម្រាប់ជំនាញបណ្តុះបណ្តាលនីមួយៗ ឱ្យសមស្របតាមបច្ចុប្បន្នភាពបច្ចេកទេស

## ៤. ទិសដៅការងារឆ្នាំ២០២៣

- ជំរុញដំណើរការគាំទ្រសហគមន៍សន្សំប្រាក់នៅតាមបណ្តារាជធានី ខេត្ត

- ជំរុញការងារអភិវឌ្ឍន៍ និងសាងសង់ផ្សារជនបទនៅតាមបណ្តាខេត្តគោលដៅ និងរៀបចំព្រឹត្តការណ៍តាំងពិព័រណ៍ផលិតផលជនបទ
- ជំរុញការផ្តល់ឥណទាន និងប្រមូលត្រឡប់មកវិញឲ្យមានប្រសិទ្ធភាព
- បន្តជំរុញ និងលើកទឹកចិត្តប្រជាពលរដ្ឋឲ្យបង្កើតសហគ្រាសខ្នាតគ្រួសារ និងខ្នាតតូច
- បន្តសកម្មភាពសហប្រតិបត្តិការជាមួយដៃគូ វិស័យឯកជន និងគម្រោងនានា
- បន្តរៀបចំឯកសារគោលការណ៍ នីតិវិធី និងឯកសារគតិយុត្តិតាមវិស័យ
- បន្តពង្រឹងសមត្ថភាពមន្ត្រីរាជការ តាមរយៈការបើកវគ្គបណ្តុះបណ្តាល សិក្ខាសាលា និងការបញ្ជូនមន្ត្រីឲ្យទៅចូលរួមកម្មវិធីបណ្តុះបណ្តាលក្នុង និងក្រៅប្រទេស
- ពង្រឹងការតាមដាន និងវាយតម្លៃ ដើម្បីធានាប្រសិទ្ធភាពនៃការអនុវត្តការងារ
- សម្របសម្រួលជាមួយមន្ទីរអភិវឌ្ឍន៍ជនបទរាជធានី ខេត្ត ឲ្យបន្តខិតខំស្វែងរកកិច្ចសហការ និងការគាំទ្រពីគម្រោងកម្មវិធី និងអង្គការនានា ក្នុងការពង្រឹងសមត្ថភាព គ.អ.ភ
- បន្តគាំទ្រដល់គម្រោងអភិវឌ្ឍន៍ភូមិចម្រុះ ដើម្បីអភិវឌ្ឍន៍ទៅជាភូមិគម្រូ
- បន្តបណ្តុះបណ្តាលដល់គ្រួសារសហគមន៍ស្តីពី សួនដំណាំគ្រួសារ និងរបៀបធ្វើជីកំប៉ុស្ត
- បន្តបណ្តុះបណ្តាលស្តីពីការត្រៀមបង្ការ និងការកាត់បន្ថយគ្រោះភ័យក្នុងសហគមន៍
- បន្តតាមដានការអនុវត្តសកម្មភាពបណ្តុះបណ្តាលរបស់មជ្ឈមណ្ឌលអភិវឌ្ឍន៍សហគមន៍ខេត្តកំពង់ស្ពឺ ខេត្តតាកែវ និងមជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទកម្ពុជា-កូរ៉េ
- សម្របសម្រួល និងសហការអនុវត្តគម្រោងហិរញ្ញប្បទានថវិកាដៃគូអភិវឌ្ឍន៍។
- ពន្លឿនក្នុងការចុះកំណត់អត្តសញ្ញាណជនជាតិដើមភាគតិចចំនួន ១៣ ភូមិ និងសម្របសម្រួលរៀបចំបទបញ្ជាផ្ទៃក្នុងសហគមន៍ចំនួន ២០ ភូមិ
- បន្តចុះសិក្សាភូមិគោលដៅបន្ថែមទៀត ដើម្បីរៀបចំចុះវាយតម្លៃកំណត់អត្តសញ្ញាណ
- បន្តចុះរៀបចំកំណត់ទីតាំងភូមិសាស្ត្រគោលរបស់សហគមន៍ជនជាតិដើមភាគតិចនៅខេត្ត និងសហគមន៍គោលដៅចំនួន ៤ខេត្ត និង ៧សហគមន៍
- សិក្សាស្រាវជ្រាវ និងចងក្រងកម្មវិធីបណ្តុះបណ្តាលមន្ត្រីរាជការ ព្រមទាំងផលិតឯកសារមេរៀន
- បណ្តុះបណ្តាលប្រជាពលរដ្ឋនៅជនបទឱ្យមានបំណិនជីវិតធន់នឹងការប្រែប្រួលអាកាសធាតុ
- រៀបចំសិក្ខាសាលាចែករំលែកចំណេះដឹង និងផ្លាស់ប្តូរបទពិសោធន៍អំពី ការអភិវឌ្ឍជនបទ
- បន្តផ្តល់ការបណ្តុះបណ្តាលជំនាញមូលដ្ឋានដល់ប្រជាជនជនបទ

## ៥. សេចក្តីសន្និដ្ឋាន

ដោយបញ្ហាកូវីដ ១៩ នៅតែបន្តឆ្លង បាននាំឲ្យប៉ះពាល់ដល់សេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា ដែលនាំឲ្យមានការកាត់បន្ថយនូវថវិកាសម្រាប់អនុវត្តសកម្មភាពនៅក្នុងកម្មវិធីទី ៣ ឆ្នាំ ២០២២ ជាលទ្ធផលនៃការអនុវត្តកម្មវិធីទី៣ "ពិពិកម្មសកម្មភាពសេដ្ឋកិច្ចជនបទ" ឆ្នាំ២០២២ ដែលតម្រូវឲ្យកាត់នូវសកម្មភាពចាំបាច់មួយចំនួន ជាលទ្ធផលនៃការអនុវត្តសកម្មភាព កម្មវិធីទី ៣ ទទួលបានត្រឹមចំនួន ......% ដែលជាលទ្ធផលមួយ

ទាបឬក៏ខ្សោយ ដែលមិនអាចឆ្លើយតបទៅនឹងផែនការសកម្មភាពប្រចាំឆ្នាំរបស់ខ្លួន និងជះឥទ្ធិពលដល់ផែនការយុទ្ធសាស្ត្ររបស់ក្រសួង និងគោលនយោបាយអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាល។